# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែវិច្ឆិកា ឆ្នាំ២០១៤
# និងទិសដៅការងារ ខែធ្នូ ឆ្នាំ២០១៤

(ពីថ្ងៃទី៣១/១០/២០១៤ ដល់ ២៥/១១/២០១៤)

ក្នុងគោលដៅចូលរួមចំណែកអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី២ឆ្នាំ២០១៤ និងទិសដៅការងារដែលបានដាក់ចេញកាលពីខែតុលាឆ្នាំ២០១៤កន្លងទៅ សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ក្នុងខែវិច្ឆិកាឆ្នាំ២០១៤នេះ តាមរយៈរបាយការណ៍ដែលផ្ញើមកអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាល និង បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, កំពង់ស្ពឺ, កំពង់ឆ្នាំង, សៀមរាប, កំពង់ធំ, បាត់ដំបង, បន្ទាយមានជ័យ, ស្ទឹងត្រែង, ក្រចេះ និង ខេត្តពោធិ៍សាត់ ។

តាមរយៈកិច្ចប្រតិបត្តិការនេះ បានបង្ហាញថា សកម្មភាពចរាចរជួញដូរ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមាននៅក្នុងដែនសមត្ថកិច្ចនៃរាជធានី ខេត្តទាំងនោះ ។ ក្នុងចំណោមបទល្មើសគ្រឿងញៀន ដែលបង្ក្រាបបាននៅក្នុងខែវិច្ឆិកានេះ មានបទល្មើសមួយចំនួនត្រូវក្រុមឈ្មួញគ្រឿងញៀនធ្វើសកម្មភាពជួញដូរចែកចាយ ក្នុងទ្រង់ទ្រាយគួរកត់សំគាល់ តែត្រូវបានកម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀន និងកម្លាំងរបស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បង្ក្រាបទាន់ពេលវេលា និងចាប់យកមេតំហ្វេតាមីនក្រាមម្សៅ សរុបប្រមាណ ២ គីឡូក្រាម ។

ជាងនេះទៀត នៅថ្ងៃទី២៦ខែវិច្ឆិកាឆ្នាំ២០១៤ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀនក្នុងទ្រង់ទ្រាយធំមួយករណី និងចាប់យកនូវវត្ថុតាងគ្រឿងញៀនក្នុងចំនួន

គួរកត់សំគាល់ ។ ព័ត៌មានលម្អិតពាក់ព័ន្ធនឹងករណីនេះ រួមទាំងវត្ថុតាងគ្រឿងញៀន ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បាននិងកំពុងរៀបចំរបាយការណ៍ ដើម្បីរាយការណ៍ជូនទៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

## II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. អំពីការងារដឹកនាំ

#### ១.១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០១៤-២០១៥ (ថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ២០១៤) បានមានប្រសាសន៍ផ្តាំផ្ញើទៅក្មួយៗសិស្សានុសិស្ស និស្សិត យុវជន និងយុវនារីទាំងអស់ថា បើស្រឡាញ់ខ្លួន, ស្រឡាញ់ឪពុកម្តាយ និងស្រឡាញ់អនាគតដ៏រុងរឿងគឺនៅឱ្យឆ្ងាយពីគ្រឿងញៀន និងត្រូវចេះណែនាំចំពោះមិត្តភក្តិអំពីគ្រោះថ្នាក់នៃការប្រើបំពានគ្រឿងញៀននិងត្រូវនិយាយថា ទេចំពោះគ្រឿងញៀន ។

#### ១.២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ និងដឹកនាំផ្ទាល់លើការងារជាគោលសំខាន់ៗ ជាអាទិ៍ ៖

- អញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ដោយឆ្លៀតក្នុងឱកាសនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានធ្វើការណែនាំបន្ថែមឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក៏ត្រូវយកចិត្តទុកដាក់ក្នុងការបង្ការកុំឱ្យមានការឆ្លងរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ក្នុងចំណោមអ្នកប្រើគ្រឿងញៀនទាំងចាក់និងជក់ ដែលទិវានេះធ្វើនៅសាលសន្និសីទចតុម្មុខ មានអ្នកចូលរួមប្រមាណ **៧០០** នាក់
- អញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះបឋមសិលាសាងសង់អគារសិក្សាកម្ពស់បីជាន់ មាន១៨បន្ទប់ នៅក្នុងវិទ្យាល័យឥន្ទ្រទេវី ដោយបានសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន និងណែនាំឱ្យយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំ និងការងារព្យាបាលឱ្យកាន់តែសកម្មថែមទៀត ដែលពិធីនេះមានអ្នកចូលរួមប្រមាណ **៤០០** នាក់
- អនុញ្ញាតជូន ឯកឧត្តម អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដឹកនាំប្រតិភូទៅចូលរួមកិច្ចប្រជុំទ្វេភាគី ត្រីភាគី ថ្នាក់រដ្ឋមន្ត្រី លើកទី១៤ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តហ្លួងព្រះបាង ប្រទេសឡាវ
- ជំរុញក្រសួងសុខាភិបាល ឱ្យរៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅខេត្តបន្ទាយមានជ័យ
- ជំរុញការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាពដែលបានរៀបចំរួច សម្រាប់ការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ
- ជំរុញការអនុវត្តនិងផ្សព្វផ្សាយនូវផែនការត្រួតពិនិត្យគ្រឿងញៀនទៅដល់ខណ្ឌ សង្កាត់

- រៀបចំប្រជុំដកបទពិសោធន៍ លើករណីជួញដូរគ្រឿងញៀនដែលបង្ក្រាបកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ និងការប្រើប្រាស់គ្រឿងញៀននៅតាមផ្ទះសំណាក់

- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការ និង តុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្រ្តព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- ប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## ២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ២.១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

នៅក្នុងខែវិច្ឆិកានេះ ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែតុលា ឆ្នាំ២០១៤ កន្លងទៅ ក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ចំនួន **០៦** គឺ ខេត្តកណ្តាល, ក្រចេះ, ព្រះវិហារ, កំពង់ចាម, កំពង់ស្ពឺ និង ខេត្តបាត់ដំបង បានធ្វើសកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន តាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ ខែ និងជាពិសេសនៅតាមសហគមន៍ ដែលមានមហាជនចូលរួមប្រមាណ **២០៥.៧៩៦** នាក់ លើ **១០.៧៧៥** នាក់ នៃខែតុលា ឆ្នាំ២០១៤ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១) ។

ក្នុងចំណោមសកម្មភាពដែលអនុវត្តទទួលបានលទ្ធផលខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តលើការងារមួយចំនួនដូចតទៅ :

- សហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ (១៣/១១/២០១៤) មានអ្នកចូលរួម **៤០០** នាក់, នៅស្រុកបន្ទាយមាស ខេត្តកំពត (១៩/១១/២០១៤) មានអ្នកចូលរួម **៤០០** នាក់
- ចូលរួមក្នុងសិក្ខាសាលាសម្របសម្រួលថ្នាក់ក្រោមជាតិ ស្តីពីការជួយគាំទ្រដល់ការអនុវត្តគម្រោងយុត្តិធម៌សហគមន៍ នៅកម្ពុជា (ថ្ងៃទី២៥/១១/២០១៤) ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន មានអ្នកចូលរួម **៧០** នាក់

- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ សាលារាជធានីភ្នំពេញ ខេត្ត បណ្តាក្រុមហ៊ុនទូរស័ព្ទចល័តរៀបចំកម្មវិធីផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក (០៥-០៧/១១/២០១៤) តាមរយៈសកម្មភាពដូចតទៅ ៖
  - ការផ្ញើសារអប់រំពីបញ្ហាគ្រឿងញៀនតាមទូរស័ព្ទដៃ និងសារជាអក្សររត់នៅលើកញ្ចក់ទូរទស្សន៍
  - ការផ្ញើសារអប់រំពីបញ្ហាគ្រឿងញៀនតាមរយៈក្រុមអ្នកអធិប្បាយទូក ង នៅមុខព្រះបរមរាជវាំង
  - ការប្រគំតន្ត្រីអប់រំពីបញ្ហាគ្រឿងញៀននៅពេលថ្ងៃ និងពេលយប់ នៅតាមគោលដៅសំខាន់ៗដែលមានមហាជនចូលរួមទស្សនាប្រមាណ **៩៥.000** នាក់
  - ការបញ្ជ្រាបសារអប់រំពីបញ្ហាគ្រឿងញៀនក្នុងកម្មវិធីប្រណាំងទូក ង នៅខេត្តសៀមរាប (មហាជនប្រមាណ **២៣.000** នាក់) និងនៅខេត្តបន្ទាយមានជ័យ (មហាជនប្រមាណ **២០.000** នាក់)
- ផ្តល់ការគាំទ្រដល់អង្គការកិច្ចសហការដើម្បីកម្ពុជា (កាកូ) ក្នុងការធ្វើសកម្មភាពផ្សព្វផ្សាយអប់រំបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ។
- រៀបចំចាត់ចែង សម្របសម្រួលនិងអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យ ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីផ្សាយផ្ទាល់របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ តាមកម្មវិធី និងប្រធានបទ ដូចខាងក្រោម ៖
  - កម្មវិធីសុវត្ថិភាពអ្នក ក្រោមប្រធានបទ **តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យយុវជនចៀសផុតពីគ្រឿងញៀន**
  - កម្មវិធីចក្ខុវិស័យកម្ពុជា ក្រោមប្រធានបទ **ការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន**
  - កម្មវិធីសភាអ៊ីនធឺណែត ក្រោមប្រធានបទ " **លទ្ធផល និងសកម្មភាពត្រួតពិនិត្យគ្រឿងញៀនក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ** "

ជាមួយនេះ តាមរយៈកម្មវិធីប្រិយមិត្តអ្នកចូលអានគេហទំព័រ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រចាំ**ខែវិច្ឆិកា** មានប្រិយមិត្តអ្នកចូលអានចំនួន **២៥.៧២៤** ដង លើ **៣៥.០៤៩** ដង នៃខែតុលា ឆ្នាំ២០១៤ ។

ក្រៅពីការងារខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានរៀបចំប័ណ្ណសរសើររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជូនដល់ ក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល ដែលមានស្នាដៃល្អក្នុងកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន **១៧០** សន្លឹក ។

## ២.២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.២.១. ការកាត់បន្ថយគ្រោះថ្នាក់

- សហការជាមួយបណ្ឌិត្យសភាននគរបាលកម្ពុជា រៀបចំកម្មវិធីផ្សព្វផ្សាយឯកសារកែសម្រួលលើកទី២ លើឯកសារបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន (ធ្វើនៅបណ្ឌិត្យសភាននគរបាលកម្ពុជា ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ អ្នកចូលរួមចំនួន **១២០** នាក់)

- ចូលរួមកិច្ចប្រជុំលើកទី២០ នៃគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ នៅថ្ងៃទី២០ខែវិច្ឆិកាឆ្នាំ២០១៤ ដែលរៀបចំដោយក្រសួងសុខាភិបាល ។

### ២.២.២. ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន ៖

- ព្រាងស្លាកសញ្ញាបង្ហាញពីសេវាព្យាបាលភាពញៀនគ្រឿងញៀនចំនួន ២ គំរូ សម្រាប់ដាក់នៅតាមមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និង នៅតាមភូមិ-ឃុំ
- សហការជាមួយក្រសួងសុខាភិបាល រៀបចំកិច្ចប្រជុំថ្នាក់សង្កាត់ ស្តីពីការអនុវត្តការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ តាមកម្មវិធីដូចខាងក្រោម ៖
  - សង្កាត់ទួលសង្កែ ព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ មានសមាសភាពចូលរួម ៣០ នាក់
  - សង្កាត់ប្រាំងចំរេះ២ ល្ងាចថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ មានសមាសភាពចូលរួម ៣០ នាក់
  - សង្កាត់ជ្រោយចង្វារ ព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ មានសមាសភាពចូលរួម ៣០ នាក់
  - សង្កាត់ច្បារអំពៅ១ ព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ មានសមាសភាពចូលរួម ៣០ នាក់
  - សង្កាត់ច្បារអំពៅ២ ល្ងាចថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ មានសមាសភាពចូលរួម ៣០ នាក់

  **សរុប ១៥០ នាក់**
- ចូលរួមសិក្ខាសាលារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីបង្គោលក្នុងការគាំទ្រដល់ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤ (អ្នកចូលរួម **៣០** នាក់)
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការខាន់ណា រៀបចំសិក្ខាសាលាស្តីពីគោលនយោបាយកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើគ្រឿងញៀន និងការព្យាបាលអ្នកញៀនគ្រឿងញៀនតាមសហគមន៍ កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៤ (អ្នកចូលរួម **៦០** នាក់)
- ជំរុញសាលារាជធានីភ្នំពេញ រៀបចំប្រជុំគណៈកម្មការ និងអនុគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ដើម្បីពង្រឹងការងារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

## ២.៣. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពក្នុងការត្រួតពិនិត្យគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី៥ឆ្នាំ២០១៤ កាលពីថ្ងៃទី២៤-២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ដល់សមត្ថកិច្ចកងរាជអាវុធហត្ថរាជធានីភ្នំពេញ ចំនួន **១២** រូប ។

ក្រៅពីនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០២ រូប, សម្របសម្រួលជូនតំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ០១ រូប, តំណាងបណ្ឌិត្យសភានគរបាលកម្ពុជា ០១ រូប, តំណាងកងរាជអាវុធហត្ថ ០១ រូប (សរុប **០៥** រូប) ដើម្បីទៅចូលរួមក្នុងសិក្ខាសាលា សន្និសីទ និងវគ្គបណ្តុះបណ្តាល ក្រោមប្រធានបទស្តីពី ៖

- ការបង្កើនសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ដើម្បីប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន (៣០-៣១/១១/២០១៤)
- ការគាំទ្រការរួមបញ្ចូលគ្នានៅអាស៊ីអាគ្នេយ៍ដើម្បីប្រសិទ្ធភាព សន្តិសុខសាធារណៈ (៣០-៣១/១១/២០១៤)
- ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់លើការងារកោសល្យវិច័យគ្រឿងញៀនថ្នាក់តំបន់ (២៤-២៧/១១/ ២០១៤) ។

ទន្ទឹមនឹងការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ បានបន្តយកចិត្តទុកដាក់ ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀន សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

- បទល្មើសគ្រឿងញៀន សរុប **១៤៥ ករណី** លើ ១២១ ករណី នៃខែតុលា ឆ្នាំ២០១៤
- ជនសង្ស័យ ឃាត់ខ្លួន សរុប **៣៤៨ នាក់** លើ ៣០៨ នាក់ នៃខែតុលា ឆ្នាំ២០១៤

ក្នុងចំនួនបទល្មើសគ្រឿងញៀន **១៤៨ ករណី** និង ជនសង្ស័យទាំង **៣៤៨ នាក់** ខាងលើគឺ :

- បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចនគរបាលជាតិ **៩១ ករណី**, ជនសង្ស័យ **២០៥ នាក់** (ស្រី ២៣ នាក់)
- បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចកងរាជអាវុធហត្ថ **៥៤ ករណី**, ជនសង្ស័យ **១៤៣ នាក់** (ស្រី ១៧ នាក់)

ក្នុងចំនួនជនសង្ស័យ ដែលបានឃាត់ខ្លួនទាំង ៣៤៨ នាក់ ខាងលើ មាន ០៥ សញ្ជាតិ គឺ ខ្មែរ ៣៣២ នាក់ (ស្រី ៤០ នាក់), វៀតណាម ០៤ នាក់ (ប្រុស), ចិន ០២ នាក់ (ប្រុស), នីហ្សេរីយ៉ា ០៨ នាក់ (ប្រុស) និង ឥណ្ឌូនេស៊ី ០២ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក**[1] មេតំហ្វេតាមីន WY ២២៦,៧៧ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ ICE ២.១៨៤,១៥ ក្រាម, កេតាមីន ២៦៧,៣៩ ក្រាម, អ៊ិចស្តាស៊ី ៥,៤០ ក្រាម និងកញ្ឆាក្រៀម ២,២៩ ក្រាម
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** ដែលបានចាប់យករួមមាន ម៉ូតូ ៥១ គ្រឿង, រថយន្ត ៣ គ្រឿង, ព្រះក់កម្ពុជា ៨.៩២៩.០០០ រៀល, ព្រះក់ថៃ ៦២០ បាត, ព្រះក់អាមេរិក ២.៤៦២ ដុល្លារ, ប្រាក់ឥណ្ឌូនេស៊ី ២៦.០០០ **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២** ។

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៥ ដីកា = មនុស្ស ៥ នាក់ (ប្រុស) ជនជាតិខ្មែរ ។

**ជាមួយនេះ** មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី ខេត្ត នៅក្នុងខែវិច្ឆកា ឆ្នាំ២០១៤ នេះ សរុបចំនួន ៧៣ ករណី = ៨៩ សំណាក ។ ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារជាតុញៀន មាន ៧២ ករណី = ៦៩ សំណាក = ៩៥,៥ % គឺ :**
  មេតំហ្វេតាមីន ICE ៦២ សំណាក = ៦៩,៦៦ %,
  មេតំហ្វេតាមីន WY ២៣ សំណាក = ២៥,៨៤ %
- **សំណាកអវិជ្ជមានសារជាតុញៀន ០១ ករណី = ០៤ សំណាក = ០៤,៤៩ %**

[1] វត្ថុតាងគ្រឿងញៀន និង ទ្រព្យសម្បត្តិចាប់យកខាងលើ មិនបានរាប់បញ្ចូលករណីបង្ក្រាបនៅក្នុងសង្កាត់បឹងសាឡាង កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ទេ

**ក្រៅពីការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន** មន្ទីរពិសោធន៍គ្រឿងញៀនបានរៀបចំទទួលក្រុមអ្នកបច្ចេកទេសមន្ទីរពិសោធន៍គ្រឿងញៀនរបស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដែលត្រូវមកពិនិត្យ វាយតម្លៃក្នុងការជួសជុលម៉ាស៊ីនវិភាគគ្រឿងញៀន GC-MS របស់មន្ទីរពិសោធន៍ អ.ជ.ប.គ.ញ ដែលខូចលែងដំណើរការ ។

## ***២.៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារជាតុគីមីផ្សំ, វត្ថុធាតុដើម និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុង ខែវិច្ឆិកាឆ្នាំ២០១៤ នេះ មានដូចតទៅ ៖

- សារជាតុគីមីចម្រុះ ដែលពាក់ព័ន្ធនឹងតារាង ទីIV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សរុបចំនួន **៤៥០.៣៥០** គ.ក្រ **៨៨** លីត្រ ក្នុងនោះ ៖
  - សារជាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ២៣២.៨៥០ គ.ក្រ និង ៨៨ លីត្រ
  - សារជាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ២១៧.៥០០ គ.ក្រ
- វត្ថុធាតុដើមមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដែលចេញអាជ្ញាបណ្ណដោយក្រសួងសុខាភិបាល និងពាក់ព័ន្ធជាមួយ តារាង **II និង តារាង** III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ១២៥ គ.ក្រ
- ឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដែលនាំចូលដោយក្រសួងសុខាភិបាល និងពាក់ព័ន្ធជាមួយ តារាង II, តារាង III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ១០ គ.ក្រ ៩៩១ ក្រាម ៩០២ មីលីក្រាម ៨០០ មីក្រូក្រាម

**ជាមួយនេះ អគ្គលេខាធិការដ្ឋាន** អ.ជ.ប.គ.ញ បាន ៖

- រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីការប្រមូលព័ត៌មានពាក់ព័ន្ធការនាំចូលសារជាតុគីមីផ្សំ និងសារជាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៤
- សម្របសម្រួលជាមួយ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីអនុវត្តនីតិវិធី ប្រគល់-ទទួល សារជាតុគីមីចំនួន ១៤ មុខ ទម្ងន់ ១៨ តោន និង ៩០០ គ.ក្រ ដែលសមត្ថកិច្ចចាប់យកពីបទប៉ុនប៉ងផលិតគ្រឿងញៀន កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២
- រៀបចំពិធីប្រគល់ប្រេងម្រះព្រៅភ្នំ ចំនួន ១.៩១៣ គីឡូក្រាម ដែលសមត្ថកិច្ចខេត្តកំពង់ឆ្នាំងចាប់យក ជូនទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- សហការជាមួយអង្គការ UNODC ដើម្បីរៀបចំបែបបទបញ្ជូនសំណាកម្សៅល្លិរមៀត ទៅធ្វើការវិភាគនៅមន្ទីរពិសោធន៍របស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ឱ្យបានច្បាស់លាស់ថាតើនៅក្នុងម្សៅនោះ មានផ្ទុកនូវសារជាតុអ្វីខ្លះ
- បន្តការរៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំកន្លងមក។

### ២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជិតខាង

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន ៖

- បន្តយកចិត្តទុកដាក់ជំរុញកិច្ចប្រជុំទ្វេភាគីថ្នាក់ខេត្ត ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម ឡាវ និង ថៃ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន

- ចូលរួមកិច្ចប្រជុំត្រីភាគី ទ្វេភាគីកម្ពុជា-ឡាវ-វៀតណាម លើកទី១៤ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី១៩-២១ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅខេត្តហ្លួងព្រះបាង ប្រទេសឡាវ ។

### ២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន និងសម្របសម្រួលជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់តំណាងទៅចូលរួមក្នុងសិក្ខាសាលា, សន្និសីទ, កិច្ចប្រជុំ, វគ្គបណ្តុះបណ្តាល ដែលខ្លឹមសារស្តីពី ៖

- ការបង្កើនសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ ដើម្បីប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន
- ការគាំទ្រការរួមបញ្ចូលគ្នានៅអាស៊ីអាគ្នេយ៍ ដើម្បីប្រសិទ្ធភាព សន្តិសុខសាធារណៈ
- ការសម្របសម្រួលផ្លាស់ប្តូរព័ត៌មានប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (APICC) លើកទី២
- ការសម្របសម្រួលសហប្រតិបត្តិការអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លើកទី២៤ (ADLOMICO)
- កិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន លើកទី៥ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន
- ការរួមបញ្ចូលគ្នានូវកម្មវិធីអនុវត្តន៍ច្បាប់គ្រឿងញៀន លើកទី១៤
- ការតម្រង់ទិសស្តីពីការអនុវត្តរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅតំបន់អាស៊ីកណ្តាល
- ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់លើការងារកោសល្យវិច័យគ្រឿងញៀនថ្នាក់តំបន់ ។

### ២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹងនិងពង្រីកលទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យឲ្យមានប្រសិទ្ធភាព អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- រៀបចំកិច្ចប្រជុំ ដើម្បីពិភាក្សាលើការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤
- ចូលរួមកិច្ចប្រជុំចង្អៀត នៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើសេចក្តីព្រាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពី ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤
- ចូលរួមក្នុងកិច្ចប្រជុំជាមួយក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងកែសម្រួល លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤
- បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- បន្តការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន

- បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តពាក់ព័ន្ធ ដើម្បីធ្វើការកែសម្រួលសមាសភាពរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែធ្នូ ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តសម្របសម្រួល ជំរុញអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. *ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ និងបដិសេធគ្រឿងញៀន*

***១.១.*** រៀបចំសម្របសម្រួល និងអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ស្តីពីសកម្មភាពពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀននៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ (ថ្ងៃទី១៧/១១/២០១៤)

***១.២.*** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន

***១.៣.*** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត និងវិស័យឯកជន ក្នុងការបង្ការទប់ស្កាត់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផលស៊ីហ្សា និងបារីអេឡិចត្រូនិច នៅតាមរាជធានី ខេត្តទូទាំងប្រទេស

***១.៤.*** សហការជាមួយក្រសួងទេសចរណ៍ ដើម្បីរៀបចំផលិតបន្ថែមនូវស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន អេដស៍ ការប្រើប្រាស់អាវុធ និងការជួញដូរមនុស្ស

***១.៥.*** បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយនានា

***១.៦.*** បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលអប់រំពីបញ្ហាគ្រឿងញៀន នៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និង នៅតាមសហគមន៍

***១.៧.*** បន្តកិច្ចសហការជាមួយក្រសួងធម្មការនិងសាសនា រៀបចំផែនការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនសម្រាប់ឆ្នាំ២០១៥

***១.៨.*** សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តគោលដៅ និងវិស័យឯកជន ដើម្បីបន្តរៀបចំកម្មវិធីប្រគំតន្ត្រីអប់រំពីបញ្ហាគ្រឿងញៀន

**១.៩.** ជំរុញសកម្មភាពចែកចាយឯកសារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនឱ្យកាន់តែសកម្មថែមទៀតនៅតំបន់គោលដៅសំខាន់ៗ ដើម្បីឱ្យអ្នករងគ្រោះអាចទៅទទួលយកសេវាព្យាបាលនៅមន្ទីរពេទ្យបង្អែក ឬ មណ្ឌលសុខភាពដែលនៅជិតផ្ទះ ។

## ២. *ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន*

**២.១.** ជំរុញក្រសួងសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅខេត្តបន្ទាយមានជ័យ សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការ *UNODC* ដើម្បីធ្វើការបូកសរុបលទ្ធផលនៃការកៀរគរថវិកាជំនួយសម្រាប់អនុវត្តកម្មវិធីផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

**២.២.** បន្តសហការជាមួយក្រសួងសុខាភិបាល រៀបចំកិច្ចប្រជុំថ្នាក់សង្កាត់ចំនួន ១៦ សង្កាត់ នៅក្នុងខណ្ឌមានជ័យ, ខណ្ឌចំការមន, ខណ្ឌទួលគោក, ខណ្ឌដូនពេញ, ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខ

**២.៣.** បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការពង្រឹងយន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

**២.៤.** បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

**២.៥.** បង្កើនសកម្មភាពអប់រំណែនាំដល់អ្នករងគ្រោះដោយសារគ្រឿងញៀន ឱ្យស្ម័គ្រចិត្តទៅទទួលយកសេវាបន្សាប ព្យាបាលភាពញៀនគ្រឿងញៀន នៅកន្លែងផ្តល់សេវាដែលបានរៀបចំ ។

## ៣. *ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់*

**៣.១.** បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទ (យោធភូមិភាគ និងវរការពារព្រំដែន)

**៣.២.** បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ

**៣.៣.** ចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០១ រូប និងសម្របសម្រួលជូនតំណាងបណ្ឌិត្យសភានគរបាលកម្ពុជា ០១ រូប ទៅទទួលវគ្គបណ្តុះបណ្តាលការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋ-កម្មឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិច នៅថ្ងៃទី០៩-១២/១២/២០១៤ នៅទីក្រុងបាងកក ប្រទេសថៃ

**៣.៤.** រៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមច្រកអាកាសយានដ្ឋានអន្តរជាតិ ។

## ៤. *ការត្រួតពិនិត្យសារធាតុគីមីផ្សំ*

**៤.១.** រៀបចំឯកសារសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់

**៤.២.** បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម

**៤.៣.** សិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

**៤.៤.** រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ***៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង***

**៥.១.** សម្របសម្រួលជាមួយប្រទេសថៃ ឡាវ វៀតណាម ក្នុងការជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងថ្នាក់ខេត្តនិងខេត្ត ស្រុកនិងស្រុកជាប់ព្រំដែនកម្ពុជា-ថៃ / កម្ពុជា-ឡាវ / កម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដោយមានការចូលរួមពីផ្នែកកងទ័ព

**៥.២.** ពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ថៃ / កម្ពុជា-ឡាវ និង កម្ពុជា-វៀតណាម

**៥.៣.** សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន ប្រទេសវៀតណាម និងប្រទេសឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសឡាវ និងប្រទេសវៀតណាម ។

## ***៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ***

**៦.១.** សម្របសម្រួលជាមួយ UNODC ដើម្បីចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០១ រូប និងតំណាងបណ្ឌិត្យសភានគរបាលកម្ពុជា ទៅទទួលវគ្គបណ្តុះបណ្តាលការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិច នៅថ្ងៃទី០៩-១២/១២/២០១៤ នៅទីក្រុងបាងកក ប្រទេសថៃ

**៦.២.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់កម្មវិធីបណ្តុះបណ្តាលចល័តស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន

**៦.៣.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ពីគម្រោង PATROL របស់អង្គការ UNODC

**៦.៤.** ត្រៀមលក្ខណៈជូនថ្នាក់ដឹកនាំជាន់ខ្ពស់នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញចូលរួមក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីបញ្ហាគ្រឿងញៀន នៅប្រទេសឥណ្ឌូនេស៊ី (ថ្ងៃទី០១-០៤/១២/២០១៤)

**៦.៥.** សម្របសម្រួលរៀបចំដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

## ***៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ***

**៧.១.** បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

**៧.២.** ជំរុញការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**៧.៣.** ជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្រ្តព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន

**៧.៤.** ជំរុញការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយនិងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន

**៧.៥.** បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកការងាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**៧.៦.** ជំរុញការរៀបចំយន្តការគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ពីថ្នាក់រាជធានីរហូតដល់ខណ្ឌ សង្កាត់ដើម្បីចូលរួមចំណែកក្នុងការគាំទ្រកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ដោយធ្វើសកម្មភាពនៅតំបន់គោលដៅសំខាន់ៗ

**៧.៧.** រៀបចំវគ្គបណ្តុះបណ្តាលអំពីអនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៅតាមក្រសួងស្ថាប័នដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**៧.៨.** រៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់ មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ នៅតាមរាជធានី ខេត្ត ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣

  "ដើម្បីជូនជ្រាប "
- ក្រសួង សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

  "ដើម្បីមុខការ "
- ឯកសារ